ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# វិបត្តិលទ្ធិប្រជាធិបតេយ្យ
# នៅកម្ពុជាក្រោយការបោះឆ្នោតឆ្នាំ១៩៩៣



ឯកឧត្តម ឧត្តមសេនីយ៍ឯក ញឹក ប៊ុនឆៃ
នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ

# មាតិការឿង


- អារម្ភកថា ២
- ដំណោះស្រាយជម្លោះកម្ពុជា ៣
- កត្តាឆ្ពោះទៅរកការមិនទុកចិត្តគ្នា ៣
- វិបត្តិក្នុងរាជរដ្ឋាភិបាលមាននាយករដ្ឋមន្ត្រីពីររូប ៥
- សកម្មភាពសំខាន់ៗរបស់លោក ហ៊ុន សែន
  ឆ្ពោះទៅរកការធ្វើរដ្ឋប្រហារ ៦
- លេសនៃការធ្វើរដ្ឋប្រហារ ៧
- រដ្ឋប្រហារដឹកនាំដោយលោក ហ៊ុន សែន ៩
- សំណើរជប៉ុន និងការកាត់ទោសរបស់តុលាការក្រុងភ្នំពេញ ១១
- ការប្រមើលមើលការបោះឆ្នោត ឆ្នាំ១៩៩៨ ១២
- សំណូមពរ ១៣
- ជីវប្រវត្តិសង្ខេប ១៥
- ឧបសម្ព័ន្ធ ក (គំនូសផែនទី) ១៧
- សេចក្តីប្រកាស លេខ ៥៣ បដិសេធការកាត់ទោស ១៨
- សេចក្តីប្រកាស លេខ ៥៥ ស្តីពីបទឈប់បាញ់ តាមសំណើរជប៉ុន ២០

# អារម្ភកថា

" ជាតិ សាសនា ព្រះមហាក្សត្រ ជាជំពីសតែមួយគត់ សំរាប់ប្រជារាស្ត្រខ្មែរ
លទ្ធិប្រជាធិបតេយ្យ ជាគោលដៅរបស់យើងទាំងអស់គ្នា "

ព្រឹត្តិការណ៍នយោបាយនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលជាងពីរទសវត្សកន្លងមកនេះ បានផ្តល់មកនូវមហាវិនាសកម្មយ៉ាងធ្ងន់ធ្ងរចំពោះមាតុភូមិកម្ពុជា ជាទីស្នេហារបស់យើង ។ ថ្វីត្បិតតែមានអន្តរាគមន៍យ៉ាងខ្លាំងក្លារបស់អង្គការសហប្រជាជាតិ ក្នុងការបញ្ចប់វិបត្តិនៅកម្ពុជាក្តីក៏ជម្លោះចេះតែបន្តដោយសារតែការខ្វះភាពស្មោះត្រង់នឹងគ្នាក្នុងសង្គមកម្ពុជាជាពិសេសរវាងថ្នាក់ដឹកនាំ ។

អត្ថបទដ៏សង្ខេបដែលខ្ញុំបានចងក្រងមកនេះ មានគោលបំណងចង់បកស្រាយបំភ្លឺជូនបងប្អូនរួមជាតិ និង អន្តរជាតិ អំពីធាតុពិតនៃសភាពការណ៍រួម ដែលបានកើតឡើងក្នុងអាណត្តិទី១នៃរាជរដ្ឋាភិបាលកម្ពុជាដែលកើតចេញមកពីការបោះឆ្នោតជាសកលនាឆ្នាំ១៩៩៣ ឧបត្ថម្ភដោយ អង្គការសហប្រជាជាតិ ។

ខ្ញុំសូមឧទ្ទិសនូវអត្ថបទនេះ ជូនចំពោះវិញ្ញាណក្ខ័ន្ធបងប្អូនរួមជាតិទាំងអស់ដែលបានលះបង់ជីវិតដើម្បីបុព្វហេតុជាតិ មាតុភូមិកម្ពុជានៃយើង ជាពិសេសចំពោះវិញ្ញាណក្ខ័ន្ធបងប្អូន ដែល បានទទួលរងគ្រោះដោយសាររដ្ឋប្រហារថ្ងៃទី ៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ។

សូមវិញ្ញាណក្ខ័ន្ធបងប្អូនទាំងអស់ ឆ្ពោះទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

ធ្វើនៅថ្ងៃទី ២៨ ខែមិនា ឆ្នាំ១៩៩៨

[illegible]

ឧត្តមសេនីយ៍ឯក ញ៉ឹក ប៊ុនឆៃ



រដ្ឋប្រហារផ្តួលរំលំ សម្តេចក្រុមព្រះ នៅ ថ្ងៃ ៥-៦ កក្កដា ១៩៩៧ ដែលរៀបចំ ដោយហ៊ុនសែន

## ការដោះស្រាយជម្លោះកម្ពុជា

ប្រទេសកម្ពុជាដែលបានរងទុក្ខវេទនាដោយសារសង្គ្រាមរ៉ាំរ៉ៃអស់រយៈជាងពីរទសវត្សកន្លងមកនេះត្រូវបានបញ្ចប់ទៅវិញតាមរយៈការអនុវត្តន៍កិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលបានតម្រូវ ឲ្យមានអន្តរាគមន៍ របស់អង្គការសហប្រជាជាតិ ។ ភាគីក្នុងជម្លោះទាំងបួនគឺ ហ៊្វុនស៊ិនប៉ិច (FUNCINPEC) រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ(KPNLF) កម្ពុជាប្រជាធិបតេយ្យឬខ្មែរក្រហម(DK) និងរដ្ឋកម្ពុជាឬគណបក្សប្រជាជន (SOC or CPP) បានចុះហត្ថលេខារួមគ្នាថា និងចូលរួមបោះឆ្នោតជាសកលមួយក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ។ តាមពិតគេមើលឃើញថា គណបក្សប្រជាជនរបស់លោក ហ៊ុន សែន ដែលកំពុងបំរើនយោបាយយួនគ្មានបំណងបញ្ចប់សង្គ្រាម ហើយរៀបចំការបោះឆ្នោតនោះទេ ។

ទោះបីជាមានការគំរាមកំហែងយ៉ាងច្រើនពីក្រុមប្រដាប់អាវុធ និងរដ្ឋអំណាចតាមមូលដ្ឋាន ភូមិ ឃុំ របស់ លោក ហ៊ុន សែន យ៉ាងណាក្តី ក៏ប្រជារាស្ត្រចំនួនជាង៩០ ភាគរយ បានប្តូរផ្តាច់ចូលរួមក្នុងការបោះឆ្នោតនេះ ដែលបានផ្តល់ការទុកចិត្តលើ គណបក្សហ៊្វុនស៊ិនប៉ិចឲ្យឈ្នះ ឆ្នោត ។ ខាងក្រោមនេះជាកលល្បិចរបស់លោក ហ៊ុន សែន ក្រោយពេលមានកិច្ចព្រមព្រៀង ក្រុងប៉ារីស ក្នុងការបំភាន់ភ្នែកសាធារណជន៖

## កត្តាផ្ទុះនៃការមិនទុកចិត្តគ្នា

- ករណីដែលលោក ខៀវ សំផន ដែលជាហត្ថលេខីក្រុងប៉ារីស តំណាងឲ្យភាគីកម្ពុជាប្រជាធិបតេយ្យ ត្រូវបានហ្វូងបាតុករវាយបែកក្បាល ក្នុងពេលដែលលោកមកដល់ទីក្រុងភ្នំពេញជាលើកដំបូង ដើម្បីចូលរួមប្រជុំក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់(SNC) នោះគឺជាល្បិចរបស់យួននិងលោក ហ៊ុន សែន ដែលមិនចង់ឲ្យខ្មែរបានសុខមិនចង់ឲ្យចប់សង្គ្រាម ។ ដោយសារអំពើហិង្សានេះហើយ ដែលធ្វើឲ្យក្រុមខ្មែរក្រហមគ្មាន ជំនឿលើលោក ហ៊ុន សែន ហើយមិនព្រមដកអាវុធឲ្យអ៊ុនតាក់ ដែលនាំមកនូវការច្បាំងគ្នារហូតមកដល់ថ្ងៃនេះ ។

- ការយកលេសថា ខ្មែរក្រហមមិនព្រមដាក់អាវុធ ហើយក៏ចោទប្រកាន់ផ្សេងៗ គឺជាកលល្បិចដែលលោក ហ៊ុន សែន មិនចង់ឱ្យអង្គការសហប្រជាជាតិដកហូតអាវុធ ពីក្រុមលោកដែរ ។ មិនត្រឹមតែប៉ុណ្ណោះ លោក ហ៊ុន សែន ទាមទារឱ្យបំពាក់អាវុធដល់កង ប្រដាប់អាវុធជាថ្មី ដើម្បីគៀបសង្កត់ គំរាមកំហែងប្រជារាស្ត្រស្លូតត្រង់ដោយយកលេស ថា ការពារខ្មែរក្រហមវាយប្រហារពេលបោះឆ្នោត ។

- ពេលឃោសនាបោះឆ្នោតឆ្នាំ១៩៩៣ សកម្មភាពនៃការវាយប្រហារ បោកគ្រាប់ បែក ការគំរាមកំហែង... គឺជាល្បិចរបស់លោក ហ៊ុន សែន និងបក្សពួកក្នុងការធ្វើវិទ្ធង្សនា ដោយចោទថាខ្មែរក្រហមអុកឡុកហើយយកលេសនេះទៅបកស្រាយថា ការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបានដោយសេរី។

- ដោយសារតែចាញ់ឆ្នោត ទោះបីអង្គការសហប្រជាជាតិប្រកាសជាផ្លូវការនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៣ ថា ការបោះឆ្នោតនៅ ឆ្នាំ១៩៩៣ បានប្រព្រឹត្តទៅដោយសេរី និង យុត្តិធម៌ក្តី ក៏លោក ហ៊ុន សែន បានបដិសេធមិនទទួល ស្គាល់លទ្ធផលនេះទេ ។

- ថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៣ លោក ហ៊ុន សែន ដែលកំពុងដើរតាមគំនិត យួន បានចាត់ឱ្យព្រះ អង្គម្ចាស់ចក្រពង្ស ដែលជាឧបនាយករដ្ឋមន្ត្រីរបស់អតីតរដ្ឋកម្ពុជា ឱ្យប្រកាសតំបន់អប្បគមន៍ចំនួន៧ខេត្ត ដែលស្ថិតនៅខាងកើតទន្លេមេគង្គ ជាប់នឹងព្រំប្រទល់ វៀតណាម ។ នេះជាល្បិចមាមមារអំណាចតាមវិធីគំរាមកំហែងដោយប្រើកម្លាំងយោធា ។

- ប្រឈមមុខនឹងគ្រោះថ្នាក់នេះ ដោយមិនចង់ឱ្យខ្មែរកាប់សម្លាប់គ្នាតទៅទៀត ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ក្នុងព្រះរាជឋានៈជាព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា ទ្រង់ព្រះតិះឱ្យបង្កើតរដ្ឋាភិបាលចម្រុះជាបណ្តោះអាសន្នមួយ ដែលមាននាយករដ្ឋមន្ត្រីពីររូប គឺសម្តេច ក្រុមព្រះ នរោត្តម រណឫទ្ធិ និងលោក ហ៊ុន សែន។ ពេលនោះការ ប៉ុនប៉ងធ្វើអប្បគមន៍ក៏បានបញ្ចប់ទៅវិញដោយស្រួល ហើយព្រះអង្គម្ចាស់ចក្រពង្សត្រូវភៀសព្រះកាយទៅនៅវៀតណាមមួយរយៈខ្លី មុននឹងបានទទួលកិច្ចសម្រុះសម្រួលឱ្យចូលមកកម្ពុជាវិញ ។

- ក្រោយមកទៀត លោក ហ៊ុន សែន ក៏បានរៀបចំឱ្យមានរដ្ឋប្រហារមួយទៀត ដែលបានឱ្យព្រះអង្គម្ចាស់ចក្រពង្ស លោក ស៊ិន សុង លោក ស៊ិន សេន ចេញដើរតួ

តែមិនបានសម្រេច ។ នៅពេលដែលបេសកកម្មនេះត្រូវបរាជ័យ លោក ហ៊ុន សែន ក៏បានបដិសេធមិនទទួលស្គាល់ក្រុមអ្នកដើរតួធ្វើរដ្ឋប្រហារនេះ ហើយចោទប្រកាន់ឱ្យតុលាការកាត់ទោសដាក់គុក ។ លោក ស៊ិន សុង ដែលកំពុងតែរស់នៅនិរទេសខ្លួនឯបរទេស បានសំដែងចេញនូវការឈឺចាប់បំផុត ។

## វិបត្តិក្នុងរាជរដ្ឋាភិបាល មាននាយករដ្ឋមន្ត្រីពីររូប

- ការខ្វែងគំនិតគ្នាធំបំផុត ហើយផ្តើមមុនគេនោះគឺ ការដែលគណបក្សប្រជាជន គឺលោក ហ៊ុន សែន សុំឱ្យចាត់ទុកថ្ងៃ *៧មករា* ជាទិវាបុណ្យជាតិដែលយើងជាអតីតអ្នកតស៊ូសេរីមិនអាចទទួលយកបាន ។ ថ្ងៃ *៧មករា* ថ្វីត្បិតតែឡកកុម្មុយនិស្ត ប៉ុល ពត បរាជ័យមែន តែវាជាថ្ងៃដែលបរទេសឈ្លានពាន និង កាន់កាប់ប្រទេសកម្ពុជា ហើយលើកបន្តុបរបបរណបមួយ គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា របស់ក្រុម លោក ហ៊ុន សែន នេះឯង ។ ម្យ៉ាងទៀត បើគោរពតាមព្រះរាជតំរិះព្រះមហាក្សត្រនោះ ការលើក យកថ្ងៃ *៧មករា* មកធ្វើជាទិវាបុណ្យជាតិសំរាប់ពេលនេះនោះ ការផ្សះផ្សាជាតិក៏ត្រូវជួបឧបសគ្គគ្មានទីបញ្ចប់ដោយនាំមកនូវការរង្កៀសចិត្តគ្នាជានិច្ចជាមួយអតីតត្រៃភាគី FUNCINPEC , KPNLF និង DK ។
- ការដែលលោក ហ៊ុន សែន គាំទ្រឲ្យការរត់ពន្ធគ្រឿងញៀននោះ ក៏ជាវិបត្តិធំណាស់ សំរាប់ខ្មែរយើង ។ ការដែលលោកអាចមានលទ្ធភាពសាងសង់សាលារៀន និងសំណង់សាធារណៈរាប់ពាន់ខ្នងនោះ គឺមកពីលោកនៅពីក្រោយខ្នងក្រុមមនុស្សឈ្មួញទុច្ចរិតទាំងនោះឯង ។ ដោយសារតែគ្រឿងញៀននេះហើយ ដែលប្រទេសកម្ពុជាបានបាត់បង់កិត្តិយស ជាប់ឈ្មោះថាជាប្រទេសរត់ពន្ធគ្រឿងញៀន ។
- សកម្មភាពរបស់លោក ហ៊ុន សែន ក្នុងការគាំទ្រក្រុមភេរវកម្មបោកគ្រាប់បែកទៅលើហ្វូងបាតុករអហិង្សាទាមទារឱ្យតុលាការមានឯករាជ្យភាពនិងយុត្តិធម៌ ដែលបានដឹកនាំដោយលោក សម រង្ស៊ី ហើយដែលបានសម្លាប់ប្រជារាស្ត្រស្លូតត្រង់ខ្មែរចំនួន ១៩នាក់ និងរបួសជាង១០០នាក់ ការបោកគ្រាប់បែកទៅលើគណបក្ស លោកតា ស៊ន សាន និង ការនៅពីក្រោយខ្នងឃាតករបាញ់សំលាប់អ្នកកាសែតដែលបរិហារកេរ្តិ៍ លោកហ៊ុន សែន

ទាំងនេះហើយដែលធ្វើឲ្យដៃគូក្នុងរាជរដ្ឋាភិបាលបាត់ជំនឿលើលោក ហ៊ុន សែន ហើយផ្តើមធ្វើការប្រឆាំង ។

- លោក ហ៊ុន សែន បានស្រែកបន្លោះឲ្យសម្តេចក្រុមព្រះ ក្នុងករណីវៀតណាមចូលឈ្លានពានកាន់កាប់ភូមិថ្នង ស្រុករមាសហែក ខេត្តព្រៃវែង ថា "*បើនរណាចង់ទៅវាយវៀតណាមនោះ លោកនឹងបើកកាំភ្លើងឲ្យ ហើយត្រៀមក្តារឡូសាច់*"។ នេះជាការមើលងាយមើលថោកខ្មែរគ្នាឯង ហើយគាំទ្រពួកឈ្លានពាន ដែលខ្មែរទូទៅមានការឈឺចាប់បំផុត ។
- លោក ហ៊ុន សែន ធ្វើមិនដឹងមិនឮ ហើយអនុញ្ញាតឲ្យជនជាតិវៀតណាម រស់នៅក្នុងស្រុកខ្មែរចំនួន ១.៦០០.០០០នាក់ ថែមទាំងបានផ្តល់អត្តសញ្ញាណប័ណ្ណ ព្រមទាំងអនុញ្ញាតឲ្យលោក ហុក ឡុងឌី បោះពុម្ពនិងចុះហត្ថលេខារួចជាស្រេច លើប័ណ្ណកាន់អាវុធធ្វើនៅវៀតណាម ហើយបានផ្តល់ឲ្យជនជាតិវៀតណាមទាំងនោះទៀតផង ។ នេះជា អំពើក្បត់ជាតិឯង ដែលមិនអាចទទួលយកបាន ។
- លោក ហ៊ុន សែន បារម្ភណាស់ខ្លាចសម្តេចក្រុមព្រះ ចាត់ការយក ប៉ុល ពត ទៅឲ្យតុលាការអន្តរជាតិកាត់ទោស ហើយពេលនោះ លោកអស់លេសអ្វីទៀត នឹងចោទប្រកាន់ដើម្បីបន្តសង្គ្រាមបំរើយុទ្ធសាស្ត្រខ្លួន ក៏ខំស្វះស្វាធ្វើរដ្ឋប្រហារដោយយោធាភ្លាម ដើម្បីកំទេចផែនការ របស់សម្តេចក្រុមព្រះ ។
- លោក ហ៊ុន សែន បានមើលឃើញនូវបរាជ័យសំរាប់ការបោះឆ្នោតនាឆ្នាំ១៩៩៨ ព្រោះថា សូម្បីតែភូមិអភិវឌ្ឍន៍ក្រាំងយ៉ូវ ដែលលោករៀបចំផ្ទាល់ក៏គ្មានអ្នកគាំទ្រលោកដែរ ។ ផ្លូវមួយវិធីតែមួយគត់របស់ លោក ហ៊ុន សែន គឺធ្វើរដ្ឋប្រហារដោយយោធា ដើម្បីកាន់អំណាចបន្ត ដោយមិនចង់អោយមានការបោះឆ្នោតនាឆ្នាំ ១៩៩៨ ។

## សកម្មភាពសំខាន់ៗ របស់លោក ហ៊ុន សែន ឆ្ពោះទៅរកការធ្វើរដ្ឋប្រហារ

- លោក ហ៊ុន សែន បានបង្កើនចំនួនអង្គរក្សផ្ទាល់ខ្លួនចំនួន ពី៣០០នាក់ រហូតដល់ ១៥០០នាក់ ព្រមទាំង បានបញ្ជាឲ្យយកកាំភ្លើងធុនធំ មានកាំភ្លើង១០៥ មម, BM២១

និងរថក្រោះ រថពាសដែក ទៅដាក់ក្នុងបរិវេណបន្ទាយរបស់លោកនៅទួលក្រសាំង (តាខ្មៅ) និងនៅក្នុងបរិវេណភូមិគ្រឹះរបស់លោក នៅវិមានឯករាជ្យ និង តាខ្មៅ ។

- លោក ហ៊ុន សែន បានដឹកគ្រាប់ពីប្រទេសវៀតណាម ហើយយកទៅដាក់ទុកក្នុងបន្ទាយសម្ងាត់ របស់លោក នៅខេត្តព្រៃវែង ស្វាយរៀង និងកំពង់ចាម ។
- លោក ហ៊ុន សែន បានបញ្ជាអោយចល័តទ័ពចូលមកក្រុងភ្នំពេញពេលចូលឆ្នាំខ្មែរ ដោយយកលេសថា មកការពារបុណ្យចូលឆ្នាំ ពេលដែលឮថាស្តេចក្រុមឃុន នរោត្តម សេរីវុឌ្ឍ យាងត្រឡប់មកកម្ពុជាវិញ នៅថ្ងៃទី ១៥ មេសា ១៩៩៧ ។
- លោក ហ៊ុន សែន បានបង្កើតកងជីវពលប្រដាប់អាវុធហូតដល់ទៅ២៥០.០០០ នាក់ នៅតាមភូមិ ឃុំ ហើយ យកលេសថាការពារខ្មែរក្រហម ។
- លោក ហ៊ុន សែន បានប្រើល្បិចបង្កើត *ខ្មែរក្រហមបង្កប់* ហើយធ្វើ ជាឱ្យពួកនោះចេញសារភាព រួចទទួលយកពួកនោះបញ្ចូលទៅក្នុងក្របខ័ណ្ឌខេមរភូមិន្ទ (បើគេស្ម័គ្រចិត្ត) នេះជាល្បិចបង្កើន ចំនួនទ័ព ។
- ថ្ងៃទី៣ កក្កដា ១៩៩៧ លោក ហ៊ុន សែន ផ្តើមបង្កជម្លោះដោយបានបញ្ជាឱ្យដកហូតអាវុធអង្គរក្សសម្តេចក្រុមព្រះ ១២០នាក់ ដែលកំពុងធ្វើដំណើរតាមផ្លូវពីកំពង់ចាមទៅភ្នំពេញ ក្នុងបេសកកម្មការពារព្រះអង្គ ត្រឡប់ពីទស្សនកិច្ចខេត្តកំពង់ចាម ។
- លោក ហ៊ុន សែន បានចូលគាល់សម្តេចម៉ែនៅព្រះបរមរាជវាំងថា និងបោសសំអាតកម្លាំង សម្តេចក្រុមព្រះចេញពីភ្នំពេញ ។
- លោក ហ៊ុន សែន បានបង្កហេតុ ដោយបញ្ជាឱ្យលោក ហុក ឡុងឌី បាញ់កំទេចដំណាក់សម្តេចក្រុមព្រះ ដែលបានធ្វើអោយអង្គរក្សរបស់ព្រះអង្គស្លាប់ ២នាក់ និងរបួសមួយចំនួន កាលពីថ្ងៃទី១៧ មិថុនា ១៩៩៧ ។

## លេសនៃការធ្វើរដ្ឋប្រហារ

លោក ហ៊ុន សែន ជាមេដឹកនាំដ៏មហាពិសពុលបំផុត សំរាប់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ ល្បិចបង្កើតបញ្ហាផ្សេងៗ ហើយទម្លាក់កំហុសទៅលើអ្នកដទៃ ល្បិចបំបែក

បំបាក់និងកាប់សម្លាប់ក្រុមអ្នកនយោបាយប្រឆាំងល្បិចពង្រីករឿងតូចអោយទៅជារឿងធំគឺជាយុទ្ធសាស្ត្ររបស់លោក ហ៊ុន សែន ក្នុងការដណ្តើមអំណាចបែបពួកកុម្មុយនិស្តផ្តាច់ការ ។ ដើម្បីធ្វើរដ្ឋប្រហារ លោក ហ៊ុន សែន បានយកលេសចោទសម្តេចក្រុមព្រះ និងសហការី អំពី៖

១- បញ្ហានាំអាវុធចូលស្រុក :

លោក ហ៊ុន សែន បានចោទសម្តេចក្រុមព្រះថាបានរត់ពន្ធអាវុធ ។ តាមពិត អាវុធដែលសម្តេចក្រុមព្រះនាំចូលជាអាវុធស្របច្បាប់ ។ មេបញ្ជាការអង្គរក្សសម្តេច ក្រុមព្រះ បានធ្វើសំណើរមកអគ្គសេនាធិការ ដើម្បីដោះស្រាយអាវុធបំពាក់ ដល់ក្រុមអង្គរក្ស ។ អគ្គសេនាធិការ បានបញ្ជូនសំណើរទៅក្រសួងការពារជាតិ ។ ក្រសួងការពារជាតិបានឱ្យ លោករដ្ឋលេខាធិការគឺឯកឧត្តម ឯក សេរីវឌ្ឍន៍ ចាត់ការទិញឱ្យ បន្ទាប់ពីមានការឯកភាពពីសម្តេចក្រុមព្រះរួចមកនោះ ។ អាវុធទាំងនោះ មានកាំភ្លើងដៃស្វ័យប្រវត្តិសំរាប់ម្នាក់១ និងកាំភ្លើងខ្លី ។ ឯកាំភ្លើងធុន RPG.2A ចំនួន ១ ដើមនោះ គឺម្ចាស់ទំនិញបានផ្តល់មករាជរដ្ឋាភិបាលកម្ពុជាដើម្បីជាការផ្សាយពាណិជ្ជកម្មរបស់គេតែប៉ុណ្ណោះ ។ អាវុធទាំងអស់នេះមានឯកសារទិញដូរនឹងដឹកនាំគ្រប់គ្រាន់ ។ មកដល់ ស្រុកខ្មែរក៏បាននាំចូល តាមច្រកកំពង់សោម និង បានត្រួតពិនិត្យដោយអាជ្ញាធរកំពង់ផែ ក្រុងព្រះសីហនុត្រឹមត្រូវ ។ ដូច្នេះ វាមិនមែនជាការរត់ពន្ធអាវុធដូច លោក ហ៊ុន សែន បានចោទប្រកាន់នោះទេ ។

២- បញ្ហាទំនាក់ទំនងជាមួយខ្មែរក្រហម :

- លោក ហ៊ុន សែន បានចំណាយប្រាក់ចំនួន ២០០.០០០ដុល្លា ឱ្យលោក ប៉ុល សារឿន នាយអគ្គសេនាធិការរង ចាត់ចែងទាក់ទងជាមួយខ្មែរក្រហមរបស់លោក អៀង សារី នៅមៃឡែន និង ប៉ៃលិន នៅពាក់កណ្តាលឆ្នាំ១៩៩៦ (យើងខ្ញុំ មានឯកសារស្តីពីការចរចានេះ)។
- ដោយចង់បញ្ចប់បញ្ហាខ្មែរក្រហម ហើយចាប់យក ប៉ុល ពត បញ្ជូនទៅតុលាការអន្តរជាតិដើម្បីកាត់ទោសនោះ សម្តេចក្រុមព្រះបានដើរតាមគន្លងរបស់ លោក ហ៊ុន សែន ដោយបានទំនាក់ទំនងជាមួយខ្មែរក្រហមសេសសល់នៅអន្លង់វែង ឱ្យចូលមករួម

រស់ជាមួយ រាជរដ្ឋាភិបាលវិញ។

- នៅពេលដែលសភាពការណ៍ខ្មែរក្រហមអន្លង់វែងកំពុងតែបែកបាក់គ្នា ហើយមានក្រុមមួយនោះបានប្រកាសថាចាប់បាន ប៉ុល ពត ភ្លាម លោក ហ៊ុន សែន ក៏ ប្រញាប់ប្រញាល់ចោទប្រកាន់សម្ដេចក្រុមព្រះថា បានទាក់ទងជាមួយខ្មែរក្រហម ដោយខុសច្បាប់ ហើយចាត់ធ្វើរដ្ឋប្រហារភ្លាមតាមយុទ្ធសាស្ត្រយួនដែលមិនចង់ឱ្យខ្មែរមានសន្តិភាពដោយចង់ទុក ប៉ុល ពត ធ្វើជាលេសដើម្បីចោទប្រកាន់គ្នា ច្បាំងសម្លាប់គ្នាតទៅទៀត ។ ចុះការដែលលោក ហ៊ុន សែន ចាត់ឱ្យ មនុស្សរបស់លោក ទៅទាក់ទងជាមួយក្រុមលោក អៀង សារី យ៉ាំង ម៉េចក៏លោក ហ៊ុន សែន មិននិយាយថា ខុសច្បាប់ផង ។
- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យបង្កើតជាគណកម្មការដើម្បីដោះស្រាយបញ្ហាខ្មែរក្រហមដែលក្នុងនោះ ឧត្តមសេនីយ៍ កែ គឹមយ៉ាន ជាប្រធាន និងខ្ញុំ ឧត្តមសេនីយ៍ ញឹក ប៊ុនឆៃ ជាអនុប្រធាន ។ បន្ទាប់មកទៀត ក៏បាន តែងតាំងជាអនុគណកម្មការពីរក្រុមដែលមួយក្រុមដឹកនាំដោយឧត្តមសេនីយ៍ ប៉ុល សារឿន មានភារកិច្ចដោះស្រាយជាមួយខ្មែរក្រហមបើកខាងត្បូងផ្លូវជាតិលេខ៥ ។ ឯមួយក្រុមទៀតដឹកនាំដោយលោកឧត្តមសេនីយ៍ ខាន់ សាវឿន មេបញ្ជាការយោធភូមិភាគទី៤ មានភារកិច្ចដោះស្រាយរឿងខ្មែរក្រហមនៅខាងជើងផ្លូវជាតិលេខ៥ ។ ការបង្កើតណកម្មការនេះមានវត្ថុបំណងរិះរកវិធីគ្រប់បែបយ៉ាង ដើម្បីធ្វើឱ្យខ្មែរក្រហមទាំងអស់លះបង់នូវការតស៊ូប្រឆាំងរបស់ខ្លួនហើយវិលត្រឡប់មករួមរស់ជាមួយសង្គមជាតិវិញ ។ ចំណែកមេដឹកនាំកំពូលៗរបស់ខ្មែរក្រហមដែលនឹងត្រូវកាត់ទោសយ៉ាងណានោះ វាអាស្រ័យទៅលើនយោបាយជាតិនិងអន្តរជាតិជាក់ស្ដែង ។ ក្នុងន័យនេះហើយដែលខ្ញុំបានខិតខំដោយមិនគិតដល់ ការនឿយហត់និងគ្រោះថ្នាក់ផ្សេងៗ ដើម្បីបញ្ចប់បញ្ហាខ្មែរក្រហមអន្លង់វែង រួចនាំយក ប៉ុល ពត ទៅជូនតុលាការអន្តរជាតិ ។

## រដ្ឋប្រហារដឹកនាំដោយលោក ហ៊ុន សែន

តាមយុទ្ធសាស្ត្រយោធាបើចង់ប្រើកម្លាំងទ័ពនៅក្នុងក្រុងភ្នំពេញ គេត្រូវតែកាត់ផ្ដាច់កម្លាំងពីខាងក្រៅជាមុនសិនទើបប្រើទ័ពវាយភ្នំពេញ ។ ហេតុនេះហើយបានជាយើងឃើញព្រឹត្តិការណ៍

ប្រតិបត្តិការយោធា របស់ លោក ហ៊ុន សែន ដូចតទៅ ៖

- លោក ហ៊ុន សែន បញ្ជាឱ្យវាយកំទេចកងឯកភាពជើងទឹកនៅព្រែកតាខែន ដែលអគ្គសេនាធិការបានដាក់ឱ្យឈរជើងនៅទីនោះ ដោយចោទថាជាកម្លាំងអនាធិបតេយ្យ ព្រោះលោក ហ៊ុន សែន យល់ថាកម្លាំងនេះសំខាន់ណាស់ អាចជំនួយមកភ្នំពេញក៏បាន ការពារផ្លូវអន្លាគមន៍ពី ពោធិសាត់, បាត់ដំបង, បន្ទាយមានជ័យ, ឧត្តរមានជ័យ, សៀមរាប, ព្រះវិហារក៏បាន ព្រោះថា បណ្តាខេត្តទាំងនោះមានកងពលចំនួន៦ ជាអតីត FUNCINPEC, KPNLF គាំទ្រសម្តេចក្រុមព្រះ ហើយអាចធ្វើអន្លាគមន៍មកភ្នំពេញបាន បើសភាពការណ៍ តម្រូវ (មើលរូប ទំព័រ ១៧)។
- លោក ហ៊ុន សែន បានបញ្ជាអោយចល័តកម្លាំងទ័ពមកពីបណ្តាខេត្តខាងកើត ទន្លេមេគង្គ មកព័ទ្ធក្រុងភ្នំពេញ មុនព្រឹត្តិការណ៍រដ្ឋប្រហារ ។
- ថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៩៧ លោក ហ៊ុន សែន បានបញ្ជាឱ្យចល័តទ័ព និងរថក្រោះ ១៥គ្រឿង ពីបន្ទាយ រថក្រោះ *អា សេ អ៊ូ* ខេត្តកំពង់ស្ពឺមកកាន់ភ្នំពេញ ។ មកដល់សាលាស្រុកភ្នំពេញ ក៏ចែកជាពីរមុខសញ្ញា ។ មុខសញ្ញាទីមួយមានរថក្រោះ ៨គ្រឿង ឆ្ពោះទៅកាន់បន្ទាយកងរក្សាព្រះអង្គនៅវត្ត ភ្សេត ស្រុកអង្គស្នួល ខេត្តកំពង់ស្ពឺ ។ មុខសញ្ញាទីពីរមានរថក្រោះ៧គ្រឿង ឆ្ពោះមកបន្ទាយកងរក្សាព្រះអង្គនៅតាំងកសាង ខាងជើងព្រលានយន្តហោះពោធិចិនតុង ។ ក្រោយពីហ៊ុំព័ទ្ធដកអាវុធអង្គរក្សសម្តេចក្រុមព្រះនៅ បន្ទាយភ្សេតរួចហើយរថក្រោះទាំងនោះបានបន្តសហការជាមួយទិសទី២ វាយចូលបន្ទាយតាំងកសាង ហើយការផ្ទុះអាវុធក៏បានចាប់ផ្តើមនៅម៉ោង ១៥.៣០នាទី នាថ្ងៃទី៥ ខែ កក្កដា ឆ្នាំ១៩៩៧ ។
- ទាហានដែលចូលរួមក្នុងរដ្ឋប្រហារ បានពាក់ផ្លាក ‘ *ហ ស*’ មានន័យថា ‘ហ៊ុន សែន’ បញ្ជាក់ថាមិនមែន ជាកងយោធពលខេមរភូមិន្ទស្របច្បាប់ទេ គឺជាកងកម្លាំងរបស់លោក ហ៊ុន សែន ដែលបានធ្វើរដ្ឋប្រហារនិងលួចឆក់ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ និង ទ្រព្យ សម្បត្តិជាតិ។

ចំណុចទាំងប៉ុន្មានខាងលើនេះគឺជាសកម្មភាពខ្លះ១ ដែលខ្ញុំស្រង់មកបញ្ជាក់ជូនបងប្អូនរួមជាតិនិងអន្តរជាតិ ដើម្បីបង្ហាញថាលោក ហ៊ុន សែន គឺជាមេក្លោងឃាតក្នុងការ

បំបិទផលប្រយោជន៍ខ្លួន ហើយជាពិសេសទៅទៀតនោះ គឺជារដ្ឋប្រហារដោយប្រើកំលាំងយោធាកាល ពី ថ្ងៃទី ៥-៦ កក្កដា ១៩៩៧ ដែលបានទម្លាក់សម្តេច ក្រុមព្រះពីមុខដំណែង និងបានកំទេចចោល នូវរបបប្រជាធិបតេយ្យសេរី ដែលអង្គការសហប្រជាជាតិប្រគល់អោយ តាមរយៈការបោះ ឆ្នោត ខែឧសភា ឆ្នាំ១៩៩៣។

## សំណើរជប៉ុន និង ការកាត់ទោសរបស់តុលាការក្រុងភ្នំពេញ

ដំណោះស្រាយនយោបាយមួយបានកើតឡើង តាមរយៈការប្រកាសជាឯកពោភាគី ដោយភាគីលោក ហ៊ុន សែន និងសម្តេចក្រុមព្រះ ក្នុងការគោរពទៅតាមសំណើរ“៤ខ” របស់រាជរដ្ឋាភិបាលជប៉ុន ដើម្បីបញ្ចប់ជម្លោះនយោបាយកម្ពុជាបច្ចុប្បន្ន ។ សំណើរ“៤ខ”នេះ បានលើក ឡើងអំពី ការកាត់ផ្តាច់ទំនាក់ទំនងជាមួយក្រុមខ្មែរក្រហម , ការឈប់បាញ់ , ការបញ្ចូលទ័ពទាំងអស់ដែលវិវាទគ្នាទៅក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទវិញ , ការគោរពបូរណភាពទឹកដីកម្ពុជា , ការកាត់ទោស , ការលើកលែងទោស និង ការចូលរួមការបោះឆ្នោតឆ្នាំ១៩៩៨របស់ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ។

រដ្ឋាភិបាលភ្នំពេញមិនបានគោរពទៅតាមអ្វីដែលខ្លួនបានប្រកាសថា គាំទ្រសំណើរជប៉ុននេះ១០០៖នោះទេ ។ លោក ហ៊ុន សែន បានចាត់ចែងឲ្យមានការកាត់ទោសជល់រួបទ្ធិឧត្តមសេនីយ៍ ញឹក ប៊ុនឆៃ និងនាយទាហានមួយចំនួនទៀត ដែលបានគាំទ្រសម្តេចក្រុមព្រះ ដែលការកាត់ទោសនេះពុំមានចែងទាល់តែសោះក្នុង សំណើរ“៤ខ”របស់ជប៉ុន ។ លើសពីនេះទៅទៀត ដើម្បីបន្តជម្លោះ លោក ហ៊ុន សែន បានសុំលើកលែងទោសថ្វាយសម្តេចក្រុមព្រះ តែបានបដិសេធការសុំលើកលែងទោសអ្នកក្រោមឱវាទរបស់ព្រះអង្គ។ នេះបង្ហាញឲ្យឃើញនូវភាព មិនត្រឹមត្រូវ មិនសមស្រប ដែលមិនអាចទទួលយកបាន ។ ទង្វើនេះមានគោលដៅបំបែកបំបាក់សាមគ្គីភាពរវាងសម្តេចក្រុមព្រះ និងអ្នកគាំទ្រព្រះអង្គ ដែល យើងទាំងអស់គ្នាត្រូវតែប្រុង ប្រយ័ត្នជាទីបំផុត ។

តុលាការក្រុងភ្នំពេញ បានបង្ហាញអោយប្រជារាស្ត្រខ្មែរ និងពិភពលោកដែលស្រឡាញ់លទ្ធិប្រជាធិបតេយ្យឃើញថា ជាតុលាការមិនឯករាជ្យ មិនអព្យាក្រឹត មិនយុត្តិធម៌ ព្រោះថា ៖

- តុលាការនេះ មិនបានស៊ើបអង្កេត វែកមុខ និងកាត់ទោសឧក្រិដ្ឋជន ជាឃាតករ កាប់សម្លាប់មន្ត្រី និងអ្នកគាំទ្រគណបក្សហ្វ៊ុនស៊ិនប៉ិច ក្នុងព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី ៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ តាមពាក្យបណ្តឹងរបស់អ្នករងគ្រោះទេ ។ ផ្ទុយទៅវិញ តុលាការនេះបែរជាយកចិត្តទុកដាក់ កាត់ទោសអ្នករងគ្រោះដោយសាររដ្ឋប្រហារ ទៅវិញ ។
- និតិវិធីនៃការកាត់ទោសមិនអាចទទួលយកបានទេ ព្រោះថា តាមច្បាប់រាល់ការចោទប្រកាន់អាចធ្វើទៅបាន ដរាបណាព្រះរាជអាជ្ញាអមតុលាការសុំបើកករណីចោទប្រកាន់ជូនទៅក្រសួងការពារជាតិ ហើយត្រូវមានការយល់ព្រមពីនាយករដ្ឋមន្ត្រីទាំងពីរ ដែលជាសហរអគ្គមេបញ្ជាការផងដែរ ។ បើមានការយល់ព្រមពីនាយករដ្ឋមន្ត្រីទាំងពីរហើយ មុនពេលការកាត់ទោសគេត្រូវតែរៀបចំពិធីមួយដើម្បីដកហូតឋានន្តរសក្តិ និងមុខងារជាបណ្តោះអាសន្ន ដើម្បីអនុញ្ញាតឱ្យព្រះរាជអាជ្ញាអមតុលាការកោះហៅសាម៉ីខ្លួនទៅស៊ើបសួរ ។ ក្នុងករណីនេះ គេពុំបានយកមកអនុវត្តទៅតាមនិតិវិធីទេ រហូតមកដល់ពេលជំនុំជំរះទោស ។ ការបកសក្តិថ្នាក់ឧត្តមសេនីយ៍ ត្រូវតែបានទទួលការអនុម័តពីសភាជាតិជាមុនហើយក៏ត្រូវប្រកាសដោយព្រះរាជក្រឹត្យ ដែលមានព្រះហស្តលេខាឡាយដោយព្រះមហាក្សត្រ ។ ក្នុងករណីនេះ បើព្រះមហាក្សត្រប្រគល់សិទ្ធិឱ្យប្រមុខរដ្ឋស្តីទីនោះ ក៏ត្រូវមានព្រះរាជក្រឹត្យស្តីពី ការប្រគល់សិទ្ធិនេះផងដែរ ។ មកទល់ពេលនេះ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ក្តី រូបខ្ញុំផ្ទាល់ក្តី មិនបានឃើញ ឬទទួលព្រះរាជក្រឹត្យនេះទេ ។

## ប្រុះមើលមើលការបោះឆ្នោត ឆ្នាំ១៩៩៨

មតិជាតិ និងអន្តរជាតិតែងតែសម្តែងការព្រួយបារម្ភចំពោះការបោះឆ្នោតនាពេលខាងមុខនេះថា តើអាចនឹងប្រព្រឹត្តទៅបានដោយសេរី យុត្តិធម៌ គួរអោយទុកចិត្តបានឬទេ ? ខាងក្រោម នេះ គឺជាបញ្ហាដែលត្រូវប្រុងប្រយ័ត្ន និងដោះស្រាយ ៖
- លោក ហ៊ុន សែន តែងតែលូកដៃចូលបំបែកបំបាក់គណបក្សប្រឆាំងជានិច្ច ដោយធ្វើអន្តរាគមន៍ គាំទ្រក្រុមបំបែកខ្លួនដែលជាការបំបែកបំបាក់ដើម្បីគ្រប់គ្រងតាមយុទ្ធ



រដ្ឋប្រហារផ្តួលរំលំ សម្តេចក្រុមព្រះ នៅ ថ្ងៃ ៥-៦ កក្កដា ១៩៩៧ ដែលរៀបចំ ដោយហ៊ុនសែន

សាស្ត្ររបស់ក្រុមកុម្មុយនិស្ត ដូចជា៖ ការគាំទ្រលោក អៀង ម៉ូលី ដែលបែកចេញពីលោកតា សឺន សាន ក្នុងគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា (BLDP) ការគាំទ្រក្រុម លោក ងួន សឿ និងក្រុមលោក គង់ មុន្នី ដែលបែកចេញពីលោក សម រង្ស៊ី របស់គណបក្សជាតិខ្មែរ(KNP) ។ ការគាំទ្រក្រុម លោក ទន់ ចាយ ដែលបែក ចេញពីសម្តេចក្រុមព្រះ របស់គណបក្ស ហ៊្វុនស៊ិនប៉ិច ។ល។ និង ។ល។

- គណកម្មការបោះឆ្នោតមានសមាជិក ១១រូប ដែលក្នុងនោះ ១០ នាក់ជាមនុស្សរបស់គណបក្សប្រជាជន ហើយ ១នាក់ទៀត គឺលោក ទា ចឹវ៉ាត់ កំពុងតែជ្រកក្រោមស្លាបរបស់លោក ហ៊ុន សែន ។
- ប្រជាជនយួនជាងមួយលាននាក់នៅក្នុងកម្ពុជាហើយបានទទួលប័ណ្ណសំគាល់ខ្លួន ជាជនជាតិខ្មែរ ។
- រចនាសម្ព័ន្ធចាត់តាំងរបស់គណបក្សប្រឆាំង ពាមមូលដ្ឋាន ភូមិ ឃុំ ស្រុក ខេត្ត ក្រុង ត្រូវក្រុមលោក ហ៊ុន សែន គំរាមកំហែង ឬកំទេចចោលអស់ ។
- កងជីវពលប្រដាប់អាវុធជាងពីរសែននាក់ កំពុងស្ថិតនៅក្រោមកណ្តាប់ដៃរបស់ លោក ហ៊ុន សែន ដែលអាចគំរាមកំហែង គៀបសង្កត់ប្រជារាស្ត្រពេលបោះឆ្នោតបាន ។

••• ដូចនេះ ការបោះឆ្នោតដោយសេរី យុត្តិធម៌ និងគួរអោយទុកចិត្តបាននោះ មិនអាចធ្វើទៅបានទេ បើពុំមានអន្តរាគមន៍ពីអន្តរជាតិអោយបានខ្លាំងក្លាទេនោះ ។

## សំណូមពរ

ស្នើសុំសហគមន៍អន្តរជាតិ អង្គការសហប្រជាជាតិ ជួយធ្វើអន្តរាគមន៍ដើម្បី ៖

- អោយមានការបោះឆ្នោតដោយសេរីយុត្តិធម៌ និងគួរអោយទុកចិត្តបានដោយមានការចូលរួមពីគ្រប់អ្នកនយោបាយទាំងអស់ ។
- ជួយរកមុខឧក្រិដ្ឋជនដែលបានសម្លាប់មនុស្សយ៉ាងសាហាវឃោរឃៅ គ្រប់ប្រភេទទាំងអស់ ជាពិសេសការកាប់សម្លាប់ដោយមូលហេតុនយោបាយដើម្បីបញ្ជូនទៅអោយតុលាការកាត់ទោស ។

- បង្ខំអោយបង្កើតតុលាការខ្មែរថ្មីមួយដែលមានលក្ខណៈឯករាជ្យ ដោយមានអ្នកច្បាប់របស់អង្គការសហប្រជាជាតិចូលរួម ព្រមទាំងជាអ្នកសង្កេតការណ៍ដើម្បីតាមឃ្លាំមើលរាល់ការកាត់ទោស ។
- បង្កើតក្រុមការងារចំរុះមួយ ដែលមានសមាសភាពមកពីភាគីទាំងសងខាង ព្រមទាំងអន្តរជាតិចុះជាប់ជាមួយផងដើម្បីតាមដានសភាពការណ៍នៃការអនុវត្តន៍កិច្ចព្រមព្រៀងតាមសំណើរជប៉ុន ជាពិសេសទាក់ទងនឹងករណីខ្មែរក្រហមនិងការឈប់បាញ់ ។

*********************************

## ជីវប្រវត្តិសង្ខេប

## របស់ឯកឧត្តម ឧត្តមសេនីយឯក ញឹក ប៊ុនឆៃ

- ឈ្មោះ កំណើត ញឹក ប៊ុនឆៃ កើតនៅថ្ងៃទី ៧ ខែកុម្ភៈ ១៩៥៨ នៅភូមិតាអុងខាងលិច ឃុំស្វាយចេក ស្រុកថ្មពួក ខេត្តបាត់ដំបង។
- ឪពុកឈ្មោះ ញឹក ឈេន (រស់) ម្ដាយឈ្មោះ អ៊ុន សាម៉េត (រស់) មានបងប្អូនចំនួន ៩ នាក់ ដែលខ្ញុំជាកូនទី២
- ការសិក្សា និងបទពិសោធន៍ការងារ
  - ១៩៦២ - ១៩៦៧ រៀននៅសាលាបឋមសិក្សា ស្វាយចេក
  - ១៩៦៨ - ១៩៧២ រៀននៅអនុវិទ្យាល័យថ្មពួក
  - ១៩៧៣ - ១៩៧៥ រៀននៅវិទ្យាល័យសម្ដេច ឪ សិរីសោភ័ណ្ឌ "ថ្នាក់ទី១ ខ.៥"
  - ១៩៧៥ - ១៩៧៦ មកដល់ខែកក្កដា រស់នៅក្រោមរបបខ្មែរក្រហម
  - ខែសីហា១៩៧៦ភៀសខ្លួនមកកាន់ប្រទេសថៃនិងរស់នៅក្នុងជំរំភៀសខ្លួនស្រុកថៃ
  - ១៩៧៧ - ១៩៧៩ ចូលរួមជាមួយ "*ចលនាតស៊ូខ្មែរ ស*" ប្រឆាំងនឹងរបបកុម្មុយនិស្តខ្មែរក្រហម ដោយបានធ្វើប្រតិបត្តិការវាយមៀរ ភ្នំត្រែ រួមជាមួយលោក វ៉ាន សារិន ។ ធ្លាប់ជាប់គុកស្រុកថៃ សរុបប្រមាណ៦ខែ ដោយមូលហេតុជ្រៀតស៊ូនៅតាម បណ្ដោយជាយដែន ត្រូវបានខ្មែរក្រហមវាយបែក ហើយរត់ចូលស្រុកថៃ ថៃក៏ចាប់ ដាក់គុក ។
  - ថ្ងៃទី០១មករា ១៩៧៩ បានចាប់ផ្ដើមតស៊ូម្ដងទៀតប្រឆាំងនឹងយួនឈ្លានពាន ដែលដំបូងខ្ញុំមានគ្នា៨នាក់ អាវុធ២ដើមនៅជំរំចាស់ខាងមុខភូមិណងម៉ាកមុនរបស់ថៃ រហូតដល់មានគ្នាប្រមាណ ២០០នាក់ទើបបានអញ្ជើញលោក គង់ ស៊ីលោះ មកដឹកនាំដោយបង្កើតចលនាឈ្មោះចលនា សេរីការជាតិកម្ពុជា (MOULINAKA)
  - ថ្ងៃទី ៣១ សីហា ១៩៨០ បានប្រកាសបង្កើតចលនាសេរីការជាតិកម្ពុជានេះ នៅភូមិស៊ិង ស្រុកសិរីសោភ័ណ្ឌ ខេត្តបាត់ដំបង ដឹកនាំដោយលោកប្រធាន គង់ ស៊ីលោះ ទីតាំងនៅប្រាសាទស្តុកកក់ (ជំរំ៣) ដែលដំបូងខ្ញុំ មានឋានៈ ជាមេក្រុម ។ បន្ទាប់មកជាមេបញ្ជាការ កងអនុសេនាធំធនាឆ្នាំ១៩៨០ ។ ឆ្នាំ១៩៨១ បានរស់នៅជំរំគោកឡុង មានឋានៈជាមេបញ្ជាការ កងអនុសេនាធំ ។
  - ១៩៨១ - ១៩៨២ រស់នៅជំរំ អូរឫស្សីស្រុក មានឋានៈជាមេបញ្ជាការកងវរៈសេនា តូចលេខ ១២៨ ក្នុងកងទ័ព ម៉ូលីណាកា ។
  - ចុងឆ្នាំ ១៩៨២ ជំរំអូរឫស្សីស្រុក និងណងចាន់ ត្រូវកងទ័ពវៀតណាមវាយបែក ហើយត្រូវថ្នាក់ លើបញ្ជាឱ្យប្ដូរមូលដ្ឋាន មករស់នៅជំរំតាម៉ូរិញ ។

- ឆ្នាំ ១៩៨៣ បានទទួលឋានៈជាមេបញ្ជាការរង កងពលធំទី១ (ម៉ូប៊ីលណាកា) នៃកងទ័ពជាតិ សីហនុ និយម (ANS) នៅពេលដែលលោក ញ៉ឹម សុផុន បានទទួលមរណភាព ។
- ខែមករា ដល់ មេសា ១៩៨៥ ចូលរៀនសាលានាយទាហានជាន់ខ្ពស់នៅឈូបប៊ុរី ប្រទេសថៃ។
- ខែមេសា ១៩៨៥ ក្រោយពេលរៀនចប់ វាយបែកជ័រតាមុំ ខ្ញុំបានផ្លាស់មូលដ្ឋាន មកនៅជ័រថ្មដូន និងថ្មរាប រហូតដល់ដើមឆ្នាំ ១៩៨៦ ។
- ខែកក្កដា ១៩៨៦ បានទទួលមុខងារថ្មីជាមេបញ្ជាការ កងវរសេនាធំលេខ១៥ ចំណុះឲ្យអគ្គសេនាធិការ នៃកងទ័ពជាតិ សីហនុ និយម ។
- ១៩៨៩ បានទទួលឋានៈជាមេបញ្ជាការរង កងពលធំលេខ ២ នៃកងទ័ពជាតិ កម្ពុជាឯករាជ្យ (ANKI) ។
- ១៩៩០ - ១៩៩១ បានទទួលឋានៈជាមេបញ្ជាការ កងពលធំលេខ ២ នៃកងទ័ពជាតិ កម្ពុជាឯករាជ្យ ។
- ពេលបោះឆ្នោត បានទទួលមុខងារជាប្រធានសន្តិសុខ របស់គណបក្ស ហ៊្វុនស៊ិនប៉ិច ។
- ក្រោយពេលបោះឆ្នោតឆ្នាំ ១៩៩៣ បានទទួលឋានៈជានាយអគ្គសេនាធិការរងនៃកងយោធពលខេមរភូមិន្ទ ។
- ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារ ៥-៦កក្កដា ១៩៩៧ បានដឹកនាំចលនាតស៊ូ (កងយោធពលខេមរភូមិន្ទដែលស្មោះត្រង់នឹងសម្តេចក្រុមព្រះ) ប្រឆាំងនឹងរដ្ឋប្រហារនិងដើម្បីទាមទារលទ្ធិប្រជាធិបតេយ្យ ។

# វិភាគស្ថានការណ៍យោធា




## សញ្ញាសំគាល់

| | |
|---|---|
| ▭ កងឯកភាពស្មោះត្រង់នឹងសម្តេចក្រុមព្រះ | |
| 2 កងពលធំលេខ២ | 3 កងពលធំលេខ៣ |
| 7 កងពលធំលេខ៧ | 8 កងពលធំលេខ៨ |
| 9 កងពលធំលេខ៩ | 12 កងពលធំលេខ១២ |
| ○ រង្វង់ការពារភ្នំពេញ | ✸ កាត់ផ្តាច់ជំនួយគាំទ្រ |

កងឯកភាពស្មោះត្រង់នឹងសម្តេចក្រុមព្រះ នៅព្រៃកគាតែន និងវត្តភ្នៀត ត្រូវបានកំលាំងលោក ហ៊ុន សែន វាយកំទេចតែពីរបីថ្ងៃប៉ុណ្ណោះមុនរដ្ឋប្រហារ ។ នេះជាផែនការកាត់ផ្តាច់កំលាំង និងផ្លូវអន្តរាគមន៍ពីក្រៅ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កងយោធពលខេមរភូមិន្ទ
អគ្គសេនាធិការ
លេខ ៥៦.ខ/អគ ·

# សេចក្តីប្រកាស

## របស់ឯកឧត្តម ឧត្តមសេនីយឯក ញ៉ឹក ប៊ុនឆៃ
## នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ

*********

ខ្ញុំ ឧត្តមសេនីយឯក ញ៉ឹក ប៊ុនឆៃ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទសូមប្រកាសជាឧឡារិក ប្រគេន ថ្វាយ និង ជំរាបជូន ព្រះថេរានុថេរៈគ្រប់ព្រះអង្គ សម្តេច បងប្អូនជនរួមជាតិ និងសហគមន៍អន្តរជាតិ ដូចតទៅ ៖

១- ប្រកាសមិនទទួលស្គាល់រាល់ការកាត់ទោសរូបខ្ញុំ ធ្វើឡើងដោយតុលាការរបស់រដ្ឋាភិបាលភ្នំពេញ ដែលជាតុលាការមិនឯករាជ្យ មិនយុត្តិធម៌ មិនអព្យាក្រឹត និងជាឧបករណ៍នៅក្រោមឥទ្ធិពលរបស់លោក ហ៊ុន សែន ។

២- បើប្រសិនជាមានការកាត់ទោសបែបនេះមែន ខ្ញុំឧត្តមសេនីយឯក ញ៉ឹក ប៊ុនឆៃ ក៏ស្នើសុំដល់រាជរដ្ឋាភិបាលជប៉ុន អោយពិនិត្យឡើងវិញនូវខ្លឹមសារនៃសំណើរស្តីពីការដោះស្រាយជម្លោះនយោបាយនៅក្នុងប្រទេសកម្ពុជានេះឡើងវិញ ។ ទន្ទឹមនឹងនោះដែរ ខ្ញុំក៏សុំអំពាវនាវឱ្យអន្តរជាតិ ជាពិសេសអង្គការសហប្រជាជាតិរៀបចំតុលាការអព្យាក្រឹតអន្តរជាតិមួយដើម្បីកាត់ទោសមេដឹកនាំរដ្ឋប្រហារ គឺលោក ហ៊ុន សែន និង បក្សពួកដែលបានប្រព្រឹត្តបទឧក្រិដ្ឋដូចខាងក្រោម ៖

ក- លោក ហ៊ុន សែន គឺជាមេដឹកនាំរដ្ឋប្រហារយោធាដែលបានទម្លាក់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ស្របច្បាប់ចេញពីតំណែង ដែលធ្វើឱ្យអន្តរាយដល់ដំណើរការប្រជាធិបតេយ្យសេរី នៅក្នុងប្រទេសកម្ពុជា ។

ខ- លោក ហ៊ុន សែន គឺជាមេឃាតករក្នុងការសម្លាប់រង្គាលយ៉ាងឃោរឃៅ ទៅលើសមាជិកជាច្រើននៃគណបក្សហ្វ៊ុនស៊ិនប៉ិច ដូចដែលមានចែងក្នុងអនុស្សារណៈរបស់អង្គការសិទ្ធិមនុស្សនៃសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ។



រដ្ឋប្រហារផ្តួលរំលំ សម្តេចក្រុមព្រះ នៅ ថ្ងៃ ៥-៦ កក្កដា ១៩៩៧ ដែលរៀបចំ ដោយហ៊ុនសែន

ក- លោក ហ៊ុន សែន ជាអ្នកនៅពីក្រោយខ្នងការរៀបចំចំពោះព្រឹត្តការណ៍បោកគ្រាប់បែកទៅលើហ្វូងបាតុករអហិង្សាមួយដែលដឹកនាំដោយលោក សម រង្ស៊ី កាលពីថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩៧ ដែលធ្វើឱ្យប្រជាពលរដ្ឋស្លូតត្រង់ ស្លាប់ និង របួសរាប់រយនាក់ និងការបោកគ្រាប់បែកទៅលើគណបក្ស ប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា របស់លោកតា សឺន សាន ក្នុងពេលកន្លងមក ព្រមទាំងជាអ្នកនៅពីក្រោយឃាតករបាញ់សម្លាប់អ្នកកាសែតប្រឆាំងក្នុងស្រុកចំនួនយ៉ាងតិចបួននាក់ក្នុងរយៈពេលត្រឹមតែ៥ឆ្នាំប៉ុណ្ណោះ ក្រោយពេលបោះឆ្នោតឆ្នាំ១៩៩៣ ។

ខ- លោក ហ៊ុន សែនបានធ្វើការទំនាក់ទំនងចរចាជាមួយក្រុមខ្មែរក្រហមខុសច្បាប់របស់លោក អៀង សារី នៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៩៦ ហើយខ្លួនក៏បានប្រកាសដោយមោទន ភាពតាមរយៈវិទ្យុ និងទូរទស្សន៍ថា *សុំកុំឱ្យនរណាយកការរំខានការងារនេះ ចាំការងារនេះចប់ខ្ញុំទើបរាយការណ៍ជូន* ។ ចំណុចនេះបង្ហាញថាលោក ហ៊ុន សែន បានរំលោភច្បាប់ទាំងស្រុង ព្រោះថាខ្លួនបានធ្វើការងារនេះ ដោយមិនបានទទួលការយល់ព្រមពីសភាជាតិជាមុន (ខ្ញុំមានឯកសារគ្រប់គ្រាន់ ស្ដីពីកិច្ចចរចានេះ) ។

គ- លោក ហ៊ុន សែន បានប្រើប្រាស់ខ្មែរក្រហមខុសច្បាប់ដូចជា កែវ ពង្ស និង ក្អន ភាព ឱ្យចេញមុខក្នុងការកាប់សម្លាប់សមាជិកគណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្សនយោបាយប្រឆាំង ជាពិសេសក្នុងព្រឹត្តិការណ៍រដ្ឋប្រហារខែកក្កដា ឆ្នាំ១៩៩៧ ។

ឃ- លោក ហ៊ុន សែន ជាអ្នកការពារឈ្មួញទុច្ចរិតរត់ពន្ធគ្រឿងញៀន ដែលពិភពលោកស្អប់ខ្ពើមនិងមិនអាចអនុគ្រោះឱ្យរួចខ្លួនបានឡើយ ។

ង- លោក ហ៊ុន សែន បានប្រឌិតបង្កើតក្រុមអ្នកធ្វើជាសាក្សី សំរាប់កាត់ទោសសម្ដេចក្រុមព្រះ និង រូបខ្ញុំតាមរយៈការបង្ខំវាយដំរបស់ទាហាន និងសមាជិកហ្វ៊ុនស៊ិនប៉ិច ដែលខ្លួនចាប់បានក្នុងព្រឹត្តិការណ៍បង្ហូរឈាមនៅថ្ងៃទី៥-៦កក្កដា ឱ្យឆ្លើយសារភាពតាម គម្រោងការរៀបរបស់ខ្លួនទាក់ទិនទៅនឹងការចោទប្រកាន់លើការដឹកនាំអាវុធ និងបញ្ជាខ្មែរក្រហម ។ អ្នករងគ្រោះទាំងនោះមួយចំនួន បានរត់គេចមករកខ្ញុំ ហើយបានបញ្ជាក់អំពីបញ្ហានេះ ។

ច- ឈុក ឡុងឌី បាននាំអាវុធចូលខុសច្បាប់ ដែលជាអាវុធស្វ័យប្រវត្តិនិងគ្រាប់រំសេវរាប់ម៉ឺនគ្រាប់ (ខ្ញុំមានឯកសារគ្រប់គ្រាន់ក្នុងករណីនេះ) ។

ឆ- ឈុក ឡុងឌី បានធ្វើប័ណ្ណអនុញ្ញាតឱ្យកាន់អាវុធ ដែលខ្លួនបានបោះពុម្ពនៅប្រទេសវៀតណាមហើយខ្លួនក៏បានចុះហត្ថលេខារួចជាស្រេចនិងបានចេញប័ណ្ណសំគាល់ខ្លួនខុសច្បាប់ឱ្យប្រជាជនយួនផងដែរ ។

ធ្វើនៅអូរស្មាច់ ថ្ងៃទី... ខែកុម្ភៈ ឆ្នាំ១៩៩៨

ឧត្ដមសេនីយ៍ឯក ញឹក ប៊ុនឆៃ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កងយោធពលខេមរភូមិន្ទ

អគ្គសេនាធិការ

លេខ ៥.៥/...៩៨/អសក

# សេចក្តីប្រកាស

## របស់នាយអគ្គសេនាធិការ ស្តីពីបទឈប់បាញ់គ្នា

- យោងតាមសេចក្តីថ្លែងការណ៍របស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា និងជាសហអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨

- ដោយបានឃើញបទបញ្ជារបស់អគ្គសេនាធិការនៃរដ្ឋាភិបាលភ្នំពេញលេខ ០៦.៩៨ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីជំហានជាក់ស្តែងអនុវត្តបទឈប់បាញ់គ្នាជាស្ថាពរ

## ប្រកាស

១ - អនុវត្តបទឈប់បាញ់គ្នាតាមសេចក្តីថ្លែងការណ៍របស់សម្តេចក្រុមព្រះ ដូចបានយោងខាងលើ ។

២- ស្នើបង្កើតគណៈកម្មការចំពោះកិច្ច (Adhoc Committee)ថ្នាក់អគ្គសេនាធិការ ដែលមានសមាសភាពមកពីភាគីទាំងសងខាង ដោយមានជំនួយពីអ្នកសង្កេតការណ៍អន្តរជាតិ ដើម្បីត្រួតពិនិត្យ កិច្ចឈប់បាញ់គ្នា បញ្ហាដែលពាក់ព័ន្ធនឹងរឿងខ្មែរក្រហម និងការបញ្ចូលកម្លាំងទៅក្នុងកងយោធពលខេមរភូមិន្ទតែមួយ ។

៣ - មិនទទួលស្គាល់បទបញ្ជាលេខ០៦.៩៨ បក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់លោក កែ គឹមយ៉ាន នាយអគ្គសេនាធិការនៃរដ្ឋាភិបាលភ្នំពេញ ដែលបានប្រើពាក្យ *ពួកក្រុមឧទ្ទាម* ចំពោះកងយោធពលខេមរភូមិន្ទ ដែលស្មោះត្រង់នឹងសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ និងជាសហអគ្គមេបញ្ជាការ នៃកងកំលាំងប្រដាប់អាវុធជាតិកម្ពុជាស្របច្បាប់ ។ ពាក្យនេះ គ្មានន័យបង្រួបបង្រួមជាតិ ដែលមិនអាចទទួលយកបាន និង ប្រាសចាកគោលគំនិតដើមនៃសំណើ ៤ខ របស់រាជរដ្ឋាភិបាលជប៉ុន ដែលភាគីទាំងសងខាងបានគាំទ្រ ។

៤ - បដិសេធការសុំឱ្យផ្តល់របាយការណ៍ ដែលទាក់ទងនឹង ចំណុចឈរជើង ចំនួនទ័ព អាវុធ ព្រមទាំងគ្រឿងបំពាក់ មុនពេលដែលមានការឯកភាពគ្នាជាគោលការណ៍ របស់គណៈកម្មការចំពោះកិច្ច ក្នុងការបញ្ចូលទ័ពទៅក្នុងក្របខ័ណ្ឌដើមវិញ ។ការដែលប្រាប់អំពីកម្លាំង ចំណុចឈរជើង និងចំនួនអាវុធ គឺសំរាប់តែពួកឧទ្ទាមដែលចុះចូលជាមួយរាជរដ្ឋាភិបាលតែប៉ុណ្ណោះ ។

ធ្វើនៅថ្ងៃទី [illegible] ខែមីនា ឆ្នាំ១៩៩៨

នាយអគ្គសេនាធិការ

<u>ចំលងជូន</u>

- ខុទ្ទកាល័យ សម្តេចក្រុមព្រះ
- គ្រប់កងឯកភាពចំណុះអគ្គសេនាធិការ
- ទុកជាឯកសារ

**ឧត្តមសេនីយឯក ញឹក ប៊ុនឆៃ**